**ជំពូកទី ១០**

# ការអភិវឌ្ឍន៍កុមារ និងការយឺតយ៉ាវនៃការលូតលាស់
# (Child Development and Development Delay)




នៅក្នុងជំពូកទី ៩ យើងបានពិភាក្សាពីហេតុចំបងខ្លះៗនៃ "*ការវិកលប្រាជ្ញា*" ។ យើងភាគច្រើនពិនិត្យរកមើលពិការភាពដែលកើតចេញពីផ្នែក**ខាងក្នុងខួរក្បាលរបស់កុមារ** ដូចជាលក្ខណៈខួរក្បាលដែលបានខូចជាផ្នែកតូចបំផុត ឬមានហេតុផលផ្សេងទៀត ដែលមិនអាចដំណើរការបានល្បឿនដូចខួរក្បាល របស់កុមារដទៃ។ នៅក្នុងជំពូកនេះយើងក៏ពិនិត្យវិធីដែលជាការវិវឌ្ឍន៍ដំបូងរបស់កុមារផងដែរ ។

ផ្អែកលើកត្តារ**ខាងក្រៅនៃក្បាលរបស់កុមារ** ដូចជានៅក្នុងឱកាសដែលកុមារត្រូវប្រើវិញ្ញាណសតិ និងសព៌ាង្គកាយរបស់ខ្លួនដើម្បីរៀនពីវត្ថុផ្សេងៗ និងមនុស្សនៅជុំវិញ។ យើងក្រឡេកមើលនៅដំណាក់កាល ឬជំហ៊ាននៃការវិវឌ្ឍន៍របស់កុមារធម្មតានិងមធ្យោបាយដែលយើងអាចជួយ "ជំរុញ " កុមារឱ្យរៀន និងធ្វើអ្វីៗឱ្យបានល្បឿនរហ័សជាងនេះ។ កង្វល់របស់យើងមិនត្រឹមតែជួយកុមារដែលវិកលប្រាជ្ញាប៉ុណ្ណោះទេ ប៉ុន្តែជួយកុមារទាំងឡាយណាដែលមានការវិវឌ្ឍន៍យឺតយ៉ាវដោយហេតុផលអ្វីក៏ដោយ ។

**ជាធម្មតា កុមារដែលមានប្រាជ្ញាយឺតក្នុងការវិវត្តន៍ ក៏យឺតក្នុងការរៀនប្រើសព៌ាង្គកាយដែរ ។** ពួកគេចាប់ផ្តើមយឺតជាងកុមារដទៃក្នុងការងើបក្បាល បង្វិលខ្លួន អង្គុយ ប្រើដៃ ឈរ ដើរ និងធ្វើអ្វីៗផ្សេងៗ។ **ពួកគេមានកាយវិការយឺតដោយសារតែការវិវត្តន៍ប្រាជ្ញាយឺត ។**

ចំពោះកុមារឯទៀតមានភាពផ្ទុយពីការពិត។ ប្រាជ្ញារបស់ពួកគេមានជាមូលដ្ឋានពេញលេញ និងមិនមានខូចទេ តែ**ភាពពិការកាយខ្លះធ្វើឱ្យពួកគេមានការលំបាក និងយឺត ដើម្បីវិវត្តការប្រើប្រាស់ប្រាជ្ញារបស់ខ្លួន**។

ឧទាហរណ៏ កុមារដែលថ្លង់ពីកំណើត ប៉ុន្តែខួរក្បាលរបស់គេមានលក្ខណៈធម្មតា នឹងស្វែងយល់ដោយលំបាកពីអ្វីដែលអ្នកផ្សេងនិយាយ និងពិបាកក្នុងការរៀននិយាយ ។ ជាលទ្ធផល នាងជារឿយៗបានបំភ្លេចនូវការផ្លាស់ប្តូរយោបល់ និងពត៌មាន។ ដោយសារតែភាសាមានសារៈសំខាន់ ដើម្បីវិវត្តប្រាជ្ញាឱ្យបានពេញលេញ នៅក្នុងមធ្យោបាយខ្លះនាងអាចហាត់ជាយឺតខាងប្រាជ្ញានៅវ័យរបស់ខ្លួន។ តែបើកុមារត្រូវបានបង្រៀន ឱ្យទំនាក់ទំនងនឹងសេចក្តីប្រាថ្នារបស់ខ្លួន និងគិតតាមរយៈ "ភាសាសញ្ញា " នៅអាយុកាលដែលកុមារដទៃរៀននិយាយ កំលាំងគិតរបស់នាង( ប្រាជ្ញា) និងជារឿយៗវិវត្តទៅដោយធម្មតា ( សូមមើលជំពូកទី ៨)




នៅទំព័របន្ទាប់ គឺជារឿងពិតបង្ហាញពីវិធី ដែលភាពពិការកាយធ្ងន់ធ្ងរអាចបណ្តាលឱ្យមានដល់ការវិវត្តន៍ប្រាជ្ញាយឺតយ៉ាវ និងមធ្យោបាយ ដែលគ្រួសាររកមធ្យោបាយជួយកូនរបស់ខ្លួនក្នុងការវិវត្តន៍អោយបានពេញលេញ។

## រឿងរបស់អេនរីក

អេនរីក បានប្រសូតចេញពីផ្ទៃមកដោយលំបាក។ គេកើតមកដោយស្លេកស្លាំង និងទន់។ គេមិនបានផ្ដើមដកដង្ហើមប្រហែល ៣ នាទី។ ជាលទ្ធផលគេបានកើតជំងឺស្លាប់ខួរក្បាលដ៏ធ្ងន់ធ្ងរ។ សព៌ាង្គកាយរបស់គេបានក្លាយជាពិបាក បត់ចុះឡើងនិងធ្វើឱ្យមានចលនាចំឡែកដែលគេពុំអាចគ្រប់គ្រងបាន។ ក្បាលរបស់គេបត់ទៅម្ខាងជារឿយៗ ហើយពិបាកក្នុងការលេប។



ដើម្បីការពារ ម្ដាយរបស់គេបានដាក់គេនៅលើកំរាលឥដ្ឋនៅកាច់ជ្រុង

ម្ដាយរបស់អេនរីក ស្រលាញ់ និងថែទាំអេនរីកតាមដែលគាត់អាចធ្វើទៅបាន។ ប៉ុន្ដែជាច្រើនឆ្នាំកន្លងផុតទៅអេនរីក មិនអាចគ្រប់គ្រងសព៌ាង្គកាយរបស់គេបានឡើយ។ ម្ដាយរបស់គេរក្សាគេនៅកំរាល់ឥដ្ឋកន្លែងកាច់ជ្រុងដើម្បីធ្វើកុំអោយគេមានការឈឺចាប់ដល់ខ្លួនឯង។ គេបានចំណាយវ័យកុមាររបស់ខ្លួនដោយគេងផ្ងារ ជើងខ្វែងពិបាកបត់បែនដូចកន្ដ្រៃ ក្បាលបត់ងើយឡើងដោយមើលទៅលើផ្ទៃដំបូល និងជញ្ជាំងឥដ្ឋកំបោរ។ នៅវ័យ ៣ ឆ្នាំ កុមារាអេនរីក បានរៀននិយាយពាក្យពីរ បីមាត់ដោយមានលំបាកយ៉ាងខ្លាំង។ នៅវ័យ៦ឆ្នាំ គេបាននិយាយច្រើនបន្ដិច។ គេស្រែក យំជាច្រើន មានកំហឹងមួរម៉ៅ ហើយមិនបានគ្រប់គ្រងការ ***បត់ជើងតូចធំ***បានឡើយ។ នៅក្នុងមធ្យោបាយដ៏ច្រើនដែលគេធ្វើនៅតែដូចកូនង៉ែតដដែល។ គ្រូពេទ្យបានអញ្ជើញទៅមើលអេនរីក បានហៅគេថា " យឺត "។ អេនរីកបានធំធាត់ឡើងហើយនៅតែគេងម្នាក់ឯងឯកន្លែងកាច់ជ្រុង។ នៅអាយុ៧ឆ្នាំ គេបានសុំកាំភ្លើងដើម្បីបាញ់សម្លាប់ខ្លួន ក្រែងម្ដាយរបស់គេយល់ពីគេបានត្រឹមត្រូវ។

បន្ទាប់ពីនោះម្ដាយនិងបងស្រីរបស់អេនរីកបានបញ្ជូនគេទៅក្រុមអ្នកធ្វើការស្ដារនីតិសម្បទារភូមិនៅក្នុងភូមិជិតខាង។ អ្នកធ្វើការបានយល់ថាអេនរីក ប្រហែលពុំដែលមានការគ្រប់គ្រងដៃនិងជើងរបស់គេទេ។ តែគេត្រូវការទំនាក់ទំនងច្រើនជាមួយអ្នកដទៃ ហើយនិងមើលអ្វីដែលកំពុងដំណើរការនៅជុំវិញខ្លួនដោយរួមទាំងនៅក្នុងជីវិតគ្រួសារ និងភូមិរបស់គេ។ តែគេអាចធ្វើដូចម្ដេចជាមួយនិងការផ្អែតតែខ្នងរបស់ខ្លួន? ម្ដាយរបស់គេ បានព្យាយាមដាក់គេអោយអង្គុយនៅលើកៅអីជាច្រើនសារតែខ្លួនរបស់គេរឹងហើយគេបានធ្លាក់ពីកៅអី ឬស្រែកយំ។



អ្នកធ្វើការភូមិនោះបានជួយគ្រួសារអេនរីក ធ្វើកៅអីពិសេសសំរាប់គេ ដោយមានខ្នើយ និងខ្សែចងចង្កេះដើម្បីជួយឱ្យគេអង្គុយត្រូវទីតាំងល្អ។ គេបានបង្រៀនម្ដាយ និង បងស្រីរបស់អេនរីកមានពីរវិធីជួយអេនរីកឱ្យអង្គុយក្នុងមធ្យោបាយដែលរក្សាខ្លួនរបស់គេកុំអោយរឹងពេក។




ជាមួយកៅអីថ្មី អេនរីកអាចអង្គុយនិងមើលអ្វីៗ ដែលកំពុងដំណើរការនៅជុំវិញខ្លួន។ គេបានភ្ញាក់ផ្អើល និងផ្ដើមចាប់អារម្មណ៏ជាមួយវត្ថុទាំងនោះ។ គេក៏អាចអង្គុយរួមតុដើម្បីញុំាអាហារជាមួយក្រុមគ្រួសារ (ទោះជាម្ដាយរបស់គេនៅបញ្ចុកអាហារក៏ដោយ)។ អ្នករាល់គ្នាបាននិយាយទៅកាន់អេនរីក ហើយគេបានផ្ដើមនិយាយជាច្រើនភ្លាមៗ។ ទោះពាក្យរបស់គេពិបាកនឹងយល់ គេបានព្យាយាមយ៉ាងខ្លាំង។ ក្រោយមកគេចាប់ផ្ដើមនិយាយបានច្បាស់ជាងមុន។ គេក៏បានប្រាប់អ្នកឯទៀតពីការប្រើប្រាស់បង្គន់អនាម័យរបស់ខ្លួន។ គេបានយល់ថាគេមិនមែនជាកូនង៉ែតទៀតទេ ហើយក៏មិនចង់អោយអ្នកផ្សេងធ្វើមកលើខ្លួនដូចខ្លួនជាទារកដែរ។



ជារៀងរាល់ថ្ងៃ បងប្អូនប្រុសស្រីរបស់អេនរីកបានទៅរៀន។ ថ្ងៃមួយអេនរីកបានអង្វរសុំទៅរៀនជាមួយ ហើយពួកគេបានរុញអេនរីកទៅទីនោះ។ ក្រោយមកអេនរីកបានទៅសាលាជារៀងរាល់ថ្ងៃ ហើយបានផ្ដើមរៀនអាន។ អេរីកបានផ្ដើមបង្កើតការគ្រប់គ្រងក្បាលរបស់ខ្លួន។ អ្នកធ្វើការក្នុងភូមិបានជួយគ្រូដើម្បីធ្វើឧបករណ៏កាន់ សៀវភៅភ្ជាប់ទៅនឹងកៅអីរុញរបស់អេនរីក ហើយក្បាលភ្ជាប់ឧបករណ៏ដែលមានដៃខ្សែដែលអាចអោយគេអាចបើកទំព័រសៀវភៅបាន។

ជីវិតរីករាយ និងពេញលេញប្រសើរជាងមុន បានចាប់ ផ្ដើមសំរាប់អេនរីក។





បងស្រីរបស់អែនរីក ដាក់គេឱ្យអង្គុយក្នុងកៅអីថ្មី

រឿងរបស់អែនរីក បង្ហាញពីការវិវត្តន៍របស់សពាង្គកាយនិងវិញ្ញាណទាំងអស់ដែលមានឥទ្ធិពលលើគ្នាទៅវិញទៅមក។ អែនរីកមានការវិវត្តន៍យឺតខាងប្រាជ្ញា ព្រោះគេពុំបានធ្វើអ្វីក្រៅតែពីគេងផ្អែកលើតែខ្នងនៅកន្លែងកាច់ជ្រុង។ សតិរបស់គេពុំមានការជំរុញ (សកម្មភាពលំហាត់ប្រាណ និងការភ្ញាក់ផ្អើល) ដែលត្រូវការអោយមាំមួន។ គេស្ទើរតែពុំអាចគ្រប់គ្រង ចលនារបស់ខ្លួនឯងបាន តែភ្នែក និងត្រចៀករបស់គេនៅល្អ។ នៅទីបំផុតនៅពេលដែលកាយរបស់គេត្រូវបានតម្រង់ដាក់នៅនឹងកន្លែង គេអាចមើលឃើញ និងទទួលបានបទពិសោធន៍ជាច្រើនពីពិភពដែលនៅជុំវិញខ្លួនគេ និងទំនាក់ទំនងជាច្រើនជាមួយអ្នកដទៃ សតិរបស់គេវិវត្តយ៉ាងលឿន។ ដោយមានជំនួយ និងការស្រមើស្រម៉ៃគេបានរៀនធ្វើវត្ថុជាច្រើនដែលរូបគេ និងក្រុមគ្រួសាររបស់គេពុំដែលសុបិន្តថា គេអាចធ្វើទៅកើត។

យើងបានឃើញពិការភាពរបស់អែនរីក ដែលបានធ្វើអោយការវិវត្តន៍ប្រាជ្ញាមានភាពយឺតយ៉ាវ។ ស្រដៀងគ្នានេះកុមារដែលមានប្រាជ្ញាអន់ ជារឿយៗយឺតយ៉ាវក្នុងការវិវត្តន៍រាង្គកាយ។ ការអភិវឌ្ឍន៍ខ្លួន និងស្មារតីមានទំនាក់ទំនងជាប់គ្នា។ បន្ទាប់ពីនេះប្រាជ្ញាដឹកនាំខ្លួន ប៉ុន្តែអាស្រ័យលើវិញ្ញាណទាំង ៥ របស់សពាង្គកាយ (ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ រសវិញ្ញាណ ឃានវិញ្ញាណ) សំរាប់ចំណេះដឹងរបស់មនុស្ស និងវត្ថុ។ អាស្រ័យហេតុនេះ :

ពិការសពាង្គកាយ → (អាច បណ្តាលអោយមាន) → ពិការប្រាជ្ញា

ពិការប្រាជ្ញា → (អាច បណ្តាលអោយមាន) → ពិការសពាង្គកាយ

**បើសិនណា** ការថែរក្សាជាពិសេសពុំត្រូវបានធ្វើឡើងសំរាប់ជួយកុមារ ដើម្បីអភិវឌ្ឍទាំងកាយ និងសតិ ឱ្យពេញលេញតាមដែលអាចធ្វើទៅបាន

តាមពិត**កុមារនិមួយៗ**មានតំរូវការជាពិសេសផ្ទាល់ខ្លួនរបស់គេ។ ឪពុកម្តាយ និងអ្នកស្តារលទ្ធភាពពលកម្មអាចព្យាយាមចង្អុលបង្ហាញ និងឆ្លើយតបនឹងតំរូវការទាំងនេះ។ (ឧទាហរណ៏ ដូចជាតំរូវការរបស់អែនរីក សំរាប់***ទីតាំង*** ពិសេស ដើម្បីអោយគេអាចមើលឃើញ និងអាចធ្វើអ្វីៗឱ្យប្រសើរឡើង)។

ប៉ុន្តែ**កុមារទាំងអស់**មានតំរូវការជាមូលដ្ឋានដូចគ្នា។ ពួកគេត្រូវការសេចក្តីស្រលាញ់ អាហារល្អៗ និងទីជំរក ហើយពួកគេត្រូវការឱកាស ដើម្បីស្វែងរករូបកាយផ្ទាល់ខ្លួន និងពិភពជុំវិញខ្លួន អោយបានពេញលេញដូចដែលពួកគេអាចធ្វើទៅកើត។

## ការជំរុញដំបូង

"***ការជំរុញ***" មានន័យថាផ្តល់ឱកាសផ្សេងៗដល់កុមារ ដើម្បីទទួលបានបទពិសោធន៍ ស្វែងរក និងលេងជាមួយវត្ថុដែលនៅជុំវិញពួកគេ។ វាមានទំនាក់ទំនងទៅនឹងចលនាសពាង្គកាយនិងការប្រើប្រាស់វិញ្ញាណទាំងអស់ដូចជា ចក្ខុវិញ្ញាណ សោតវិញ្ញាណ កាយវិញ្ញាណ។

ការជំរុញដំបូងជាការចាំបាច់សំរាប់ការចំរើនសុខភាពរបស់សពាង្គកាយ និងសតិរបស់កុមារ។ ចំពោះកុមារមិនពិការ ការជំរុញតែងតែកើតមានឡើងជាធម្មតា និងកើតឡើងដោយងាយ ទោះបីកុមារទទួលបទពិសោធន៍ និងស្វែងរកពិភពជុំវិញខ្លួនគេក៏ដោយ។ ចំពោះសតិ និង សពាង្គកាយសំរាប់វិវត្តន៍ជាដំបូង និងពេញលេញដូចដែលអាចកើតឡើង កុមារនឹងត្រូវការ ការថែរក្សាបន្ថែម និងសកម្មភាពពិសេសដែលផ្តល់អោយនូវវិធីងាយស្រួល និងរីករាយក្នុងការរៀនសូត្រ។

**កុមារកាន់តែក្មេង នៅពេលដែល "កម្មវិធីជំរុញ" ចាប់ផ្តើម**
**កុមារកាន់តែយឺតយ៉ាវ និងយឺតពេលដែលធ្វើឱ្យគេកាន់តែធំឡើងៗ**

# ការវិវត្តន៍របស់កុមារធម្មតា




កុមារពិការវិវត្តនៅក្នុងលំដាប់ពិសេសជាបន្តបន្ទាប់ ដូចជាការសាងសង់សំណង់ដែរ។

ដើម្បីដឹងពីវិធីដែលកុមារមានការវិវត្តន៍ល្អយ៉ាងណា និងកន្លែងណាគេត្រូវការជំនួយពិសេសយើងអាចធ្វើការប្រៀបធៀបការវិវត្តន៍របស់គេជាមួយកុមារដទៃ។

**ការស្វែងយល់ពីការវិវត្តន៍របស់** *កុមារធម្មតា* **អាចណែនាំយើងក្នុងការធ្វើផែនការសកម្មភាព ដែលនឹងជួយកុមារពិការឱ្យមានការចំរើន។**

កុមារគ្រប់រូបវិវត្តក្នុងចំនុចសំខាន់ ៣ គឺ**កាយ** (សពាង្គកាយ) **ប្រាជ្ញា**(សតិ) និង**សង្គម** (ការទំនាក់ទំនង និងការប្រាស្រ័យទាក់ទងនិងមនុស្សដទៃ)។ នៅក្នុងចំនុចនីមួយៗកុមារបង្កើតជំហ៊ានជំនាញតាមជំហ៊ានលំដាប់ពិតមួយ។ នៅអំឡុងពេលលើកទី ១ សំរាប់ជីវិតជាធម្មតា ទារកទទួលនូវការគ្រប់គ្រងសពាង្គកាយរបស់ខ្លួនច្រើនឡើងៗ។

ការគ្រប់គ្រងរបស់ទារកវិវត្តលូតលាស់ពីផ្នែកក្បាលចុះក្រោមៈ






ដំបូងពិនិត្យភ្នែក និងក្បាល

បន្ទាប់មកពិនិត្យប្រអប់ដៃ និងដៃ

ពិនិត្យខ្លួន ការអង្គុយ និងលំនឹង

បញ្ចប់ពិនិត្យជើង

មុនពេលដែលកុមារអាចដើរ កុមារត្រូវការឆ្លងកាត់ដំណាក់កាល ឬ"ក៏រិត" វិវត្តជាស៊េរី។ ដំបូងកុមារត្រូវតែអាចទប់ក្បាល និងមើលពីអ្វីៗនៅជុំវិញខ្លួន។ សកម្មភាពនេះជំរុញអោយគេប្រើដៃ និងប្រអប់ដៃដើម្បីឱ្យគេអាចងើបអង្គុយបាន។ ខណៈ ពេលអង្គុយកុមារផ្តើមឈោង ផ្អែក និងងាកខ្លួន។ សកម្មភាពទាំងនេះជួយកុមារអោយវិវត្តលំនឹង និងធ្វើការផ្លាស់ប្តូរទំងន់ពីម្ខាងទៅម្ខាង ដូចជាជំនាញភ្លាមៗដែលត្រូវការសំរាប់ឈរ និងដើរ។ ជាធម្មតាការជំរុញដែលកុមារត្រូវការដើម្បីរីកលូតលាស់តាមរយៈណាក់កាលទាំងនេះ កើតចេញពីការប្រតិកម្មប្រចាំថ្ងៃជាមួយមនុស្ស និងវត្ថុផ្សេងៗ។

ទោះជាយ៉ាងនេះក្តី កុមារពិការអាចត្រូវការជំនួយពិសេសដើម្បីលូតលាស់។ ចូរសំគាល់ថានៅក្នុងឧទាហរណ៍ខាងលើការមើលឃើញរបស់កុមារពិការ **ធ្វើអោយគេមើលឃើញវត្ថុ និងចង់ឈោងចាប់វត្ថុនោះ និងធ្វើការស្វែងរក**។ ការមើលឃើញជំរុញអោយកុមារព្យាយាមរៀនសូត្រ និងធ្វើការងារជាច្រើន។ ប្រសិនបើកុមារពុំអាចមើលឃើញជាមូលដ្ឋាននៃការជំរុញដំបូងនេះនឹងមានកង្វះខាត។ ដើម្បីទប់ស្កាត់កុមារពីការតាមពុំទាន់ យើងត្រូវតែស្វែងរកវិធីលើកទឹកចិត្តកុមារឱ្យរៀន និងធ្វើអ្វីៗ។ យើងអាចធ្វើការជំរុញនេះ តាមរយៈ**ការស្តាប និងការបញ្ចេញសំលេង** ដោយទំលាប់ប្រភេទជំរុញដែលយើងប្រើចំពោះដំណាក់កាលពិសេសនៃការវិវត្តន៍របស់កុមារ។ ឧទាហរណ៍ **ប្រសិនបើកុមារពុំអាចមើលឃើញៈ**

ដំបូងយើងគួរកាន់កុមារ ហើយនិយាយទៅកាន់គេឱ្យច្រើន។ ជួយគេឈោងស្ទាប និងធ្វើឱ្យមានអារម្មណ៍ផ្សេងគ្នាពីវត្ថុនោះ

ក្រោយមក យើងលើកទឹកចិត្តគេឱ្យលើក និងងាកក្បាល និងបន្ទាប់មកទៀតឈោងដៃទៅរកសំលេងផ្សេងគ្នា។

នៅពេលកុមារចាប់ផ្តើមអង្គុយ យើងជួយគេជាថ្មីទៀត ដើម្បីសំគាល់សំលេងផ្សេង និងឈោងដៃរកសំលេងទាំងនោះ

នៅពេលកុមារចាប់ផ្តើមដើរ យើងអាចជួយគេរកផ្លូវតាមរយៈឈើនាំ និងវិធីផ្សេងទៀត




ចំពោះវិធីជួយកុមារដែលពុំអាចមើលឃើញផ្សេងៗទៀត សូមមើលជំពូកទី ៧។

ជាការសំខាន់សំរាប់ឪពុកម្តាយដឹងច្បាស់ថា កុមារវិវត្តការគ្រប់គ្រង និងប្រើកាយរបស់គេនៅក្នុងលំដាប់ខ្លះ : ការគ្រប់គ្រងក្បាល →ការគ្រប់គ្រង ***ដងខ្លួន***(ការអង្គុយ និងលំនឹង) →ការឈរ និងដើរ

នេះជាព្រឹត្តិការណ៍មួយសំរាប់កុមារធំបន្តិច។ ឪពុកម្តាយដែលមានកូនយឺត ជាញឹកញាប់នឹងព្យាយាមជួយគេឱ្យរៀនជំនាញបានខ្ពស់(ដែលកុមារដទៃទៀតដល់វ័យទើបរៀន) មុនពេលដែលគេប្រុងប្រៀបខ្លួន។ ការជួយនេះនឹងងាករកការអាក់អន់ចិត្ត និងខកចិត្តដល់ទាំងឪពុកម្តាយ និងកុមារខ្លួនឯង។




ឧទាហរណ៍ នីណា ជាកុមារីដែលមានអាយុ៣ឆ្នាំ ហើយនាងមានជំងឺខូចខួរក្បាល។ នាងនៅតែមានកង្វល់ចំពោះការងើបក្បាលឡើង ឬអង្គុយពុំកើត។



ប៉ុន្តែម្តាយរបស់នាងប្រាកដថានាងស្ទើរតែ "ប្រុងប្រៀបរៀនដើរ"។ គាត់បានទប់ នីណា ឱ្យឈរ ហើយធ្វើចលនាឱ្យនាងរំកិលទៅមុខបី ឬបួនដងក្នុងមួយថ្ងៃៗ ដូច្នេះជើងរបស់នាងរឹង ជំហ៊ានកន្ត្រាក់ៗនៅចុងជើង។ ម្តាយរបស់នាងពុំដឹងថាការបោះជំហ៊ាននោះជាការឆ្លុះបញ្ចាំងលើកដំបូងទេ ដែលតាមធម្មតាគេឃើញកើតឡើងតែចំពោះកុមារតូច(សូមមើលទំព័រទី ១២៩)។ វាមានន័យថា តាមវិធីខ្លះការវិវត្តន៍របស់ នីណា នៅមានកំរិតស្មើនិងកុមារអាយុពី ១ទៅ៣ខែ។ នាងពុំទាន់ប្រុងប្រៀបដើរនៅឡើយទេ។ ការធ្វើឱ្យនាងបោះជំហ៊ាននឹងគ្រាន់តែធ្វើឱ្យសកម្មចំពោះការឆ្លុះបញ្ចាំងដំបូងដែលនាងត្រូវការបំបាត់ដើម្បីរៀនដើរពិតប្រាកដ។



យើងត្រូវតែជួយម្តាយរបស់ នីណា ដើម្បីអោយបានដឹងដែលមានជំហ៊ានវិវត្តសំខាន់ផ្សេងទៀត មុនពេលដែលនាង ដើម្បីជួយនាងឱ្យមានការវិវត្តន៍បន្ថែមទៀត ម្តាយរបស់នាងត្រូវការៈ

១. ស្វែងយល់ពីវ័យ ឬដំណាក់កាលនៃការវិវត្តន៍របស់កុមារ
២. សំរេចថា តើអ្វីជាជំហ៊ានបន្ទាប់ធ្វើដូចនេះ កុមារអាចបង្កើតជំនាញថ្មីពីលើអ្វីដែលកុមារមានរួចហើយ**ដូចគ្នានឹងលំដាប់កុមារធម្មតាវិវត្តដែរ**។

ដើម្បីធ្វើរឿងទាំងអស់នេះ ម្តាយរបស់ នីណា គួរតែសង្កេតជាដំបូងចំពោះកុមារដោយប្រុងប្រយ័ត្ន។ នៅចំនុចនីមួយៗនៃការវិវត្តន៍ គាត់អាចកត់ចំណាំពីអ្វីផ្សេងៗដែល នីណា**អាច**ធ្វើបាន **មិនអាច**ធ្វើបាន **និងអ្វីដែលនាងទើបតែចាប់ផ្តើម ឬកំពុងតែព្យាយាមធ្វើ** តែនាងនៅតែមានបញ្ហាពីវានៅឡើយ។ បន្ទាប់ពីម្តាយរបស់នាងធ្វើការប្រៀបធៀបអ្វីដែល នីណាអាច និងមិនអាចធ្វើជាមួយកុមារដទៃដែលមានអាយុដូចនីណាអាចធ្វើបាន។ ក្រោយមកគាត់អាចសំរេចថា កូនរបស់គាត់ឋិតនៅកំរិតណានៃការវិវត្តន៍ និងសំរេចពីជំហ៊ានបន្ទាប់នូវអ្វីដែលត្រូវធ្វើបន្ត។

## តារាងស្តីពីការវិវត្តន៍របស់កុមារធម្មតា

តារាងនៅក្នុងទំព័របន្ទាប់បង្ហាញពីជំហ៊ានខ្លះៗ ឬក៏ជាវិធីវាស់វែងនៃការវិវត្តន៍របស់កុមារធម្មតា។ អ្នកអាចប្រើវាដើម្បីស្វែងយល់ពីកន្លែងដែលកុមារឋិតក្នុងការវិវត្តន៍របស់ខ្លួន និងរៀបចំផែនការជំហ៊ានបន្ទាប់ដែលកុមារត្រូវការជំនួយ។

> ***ប្រយ័ត្ន***: តារាងនៃការវិវត្តន៍បង្ហាញពីអាយុមធ្យម នៅពេលដែលកុមារចាប់ផ្តើមធ្វើអ្វីៗ ប៉ុន្តែនៅវ័យដែលកុមារធម្មតាវិវត្តជំនាញផ្សេងៗយ៉ាងខ្លាំង ដោយគ្រាន់តែកុមារមិនបានវិវត្តជំនាញខ្លះៗ នៅក្នុងអាយុដែលបានបង្ហាញនោះមិនមានន័យថា កុមារវិវត្តថយក្រោយ ឬមានបញ្ហាទេ។ សូមក្រឡេកមើលកុមារទាំងអស់ឱ្យបានច្បាស់។

**វិធីប្រើតារាងវិវត្តន៍របស់កុមារ**

តារាងនៅខាងក្នុងអាចត្រូវបានប្រើប្រាស់ :

១. ស្វែងរក និងកត់ត្រាពីកំរិតនៃការវិវត្តន៍របស់កុមារ

២. ធ្វើផែនការជំហ៊ាន ឬសកម្មភាពវិវត្តន៍បន្ទាប់ដែលយើងអាចជួយកុមារ

៣. ធ្វើការតក់ត្រាពីចំនុចដែលកុមារកំពុងរីកចំរើន និងរីកចំរើនបានច្រើនប៉ុណ្ណា ។

យើងឧបមាថា អ្នកធ្វើការខាងសុខភាពភូមិចង់ជួយម្តាយរបស់ នីណា ដើម្បីស្វែងយល់ពីអ្វីដែលគាត់ត្រូវការធ្វើបន្ទាប់ដើម្បីជួយកូនស្រីអាយុ ៣ឆ្នាំ របស់គាត់វិវត្តសមត្ថភាពដំបូង១ ។ ពួកគេពិនិត្យតារាងទាំងអស់គ្នា ។

ដំបូងពួកគេគូសរង្វង់នូវអ្វីដែលនីណាអាចធ្វើបាន ។ ព្រោះនាងមានបញ្ហាចំពោះការងើបក្បាល ដូចនេះពួកគេគូសរង្វង់ត្រង់នេះ ។

នីណា ត្រូវការជំនួយដើម្បីបង្វិលពីផ្ទៃកពោះទៅផ្ទៃកខ្នង ដូចនេះពួកគេគូសរង្វង់ដែលនៅកន្លែងផ្ទែក "បង្វិលពីផ្ទៃកពោះទៅផ្ទៃកខ្នង" ។

បន្ទាប់ពីពួកគេគូសកំរិតនៅក្នុងចំនុចនៃការវិវត្តន៍របស់នីណារួច ពួកគេអាចយល់ពីចលនាទូទៅ និងការគ្រប់គ្រងនៃរាងកាយ ។ នីណាឋិតនៅក្នុងកំរិតអាយុ ២-៤ ខែ ។ ការគ្រប់គ្រងដៃរបស់នាងមានអាយុប្រហែល ៦ខែ ។ ភ្នែក និងត្រចៀករបស់នាងមានលក្ខណៈធម្មតា និងការវិវត្តន៍ប្រាជ្ញា គឺប្រហែលក្នុងវ័យ ២ឆ្នាំ ។

បន្ទាប់មកគេគូសប្រអប់បួនជ្រុងនៅក្នុងជំហ៊ានបន្ទាប់១ពីរង្វង់និមួយ១ ។ **ប្រអប់បួនជ្រុងបង្ហាញពីជំហ៊ានដែលនីណាត្រូវការជំនួយ** ។ ដោយសារតែការគ្រប់គ្រងក្បាលលំបាករបស់នីណា ដែលកំពុងតែទប់ខ្នងរបស់នាងទៅផ្ទៃកម្ខាងទៀត ពួកគេសំរេចធ្វើការជាច្រើនដោយប្រើមធ្យោបាយនេះ( មើលទំព័រ ១២០) និងជួយនាងដោយបង្វិល និងងាកខ្លួន( មើលទំព័រ ១២២ ) ។ ប្រហែលពួកគេចាប់ផ្តើមដោយប្រើវិធីអង្គុយ និងវារ ប៉ុន្តែប្រហែលជានាងនឹងមិនមានការលូតលាស់ប៉ុន្មានទេ ។ ជាមួយមធ្យោបាយ



ទាំងនេះ លុះត្រាតែនាងមានការគ្រប់គ្រងក្បាលប្រសើរឡើង ។ ការប្រើប្រាស់ដៃ ជាអ្វីដែលឋិតនៅពីក្រោយវ័យរបស់នាង ប៉ុន្តែវិធីនេះអាចដោយឡែកពីគ្នាព្រោះតែការគ្រប់គ្រងក្បាលពិបាក ។ ដូចនេះពួកគេសំរេចរៀបចំអោយនាងអង្គុយនៅលើកៅអីពិសេសមានរយៈពេលខ្លី១ក្នុងមួយថ្ងៃ១ ដោយមានវត្ថុទប់ទ្រក្បាលរបស់នាងនៅទីតាំងល្អមួយ ពួកគេផ្តល់ល្បែងអោយនាងលេង និងវត្ថុផ្សេង១ឱ្យនាងធ្វើដើម្បីជួយនាងឱ្យវិវត្តក្នុងការប្រើដៃរបស់ខ្លួន ។ ប៉ុន្តែពួកគេប្រយ័ត្ន *មិន* ត្រូវទប់ទ្រក្បាលរបស់នាងយូរពេកទេ ព្រោះនឹងមិនអាចជួយអោយនាងរៀនទប់ដោយខ្លួនឯង ។ ពួកគេប្រុងប្រយ័ត្នផងដែរ គឺផ្តល់តែការទប់ទ្រមួយចំនួនតូចដែលត្រូវការ ដើម្បីផ្តល់ការគ្រប់គ្រងរាងកាយរបស់នាងឱ្យបានប្រសើរឡើង ។ ពួកគេកាត់បន្ថយការទប់ទ្រនាង នៅពេលដែលការគ្រប់គ្រងរបស់នាងកែលំអបានកាន់ប្រសើរឡើង ។

ព្រោះតែភ្នែក ត្រចៀក សតិ និងការនិយាយរបស់នាង ហាក់កំពុងវិវត្តន៍ប្រសើរគ្រាន់បើ នេះប្រហែលជាអ្វីដែលនាងរៀនប្រើដោយអស់លទ្ធភាពនៅពេលចំរើនវ័យឡើង ។ អាស្រ័យហេតុនេះហើយ ទើបឪពុកម្តាយរបស់នាងសំរេចចិត្តធ្វើអ្វី១ទាំងអស់ ដែលពួកគេអាចធ្វើបានដើម្បីជួយនាងកែលំអជំនាញទាំងនេះ ។ ពួកគេប្រើរូបភាព ចំរៀង រឿង លេង និងការជំរុញជាច្រើន ដើម្បីជួយឱ្យវិវត្តសតិរបស់នាង ។ ប៉ុន្តែពួកគេចាំថានាងមានវ័យ៣ឆ្នាំនៅឡើយ ។ ពួកគេមិនត្រូវជំរុញនាងខ្លាំងពេកទេ ។ ជូនកាលជាការប្រសើរ ដែលជួយនាងឱ្យទទួលបាននូវជំនាញ និងការជឿជាក់ ២ ឬ៣មុខ ពេលតែមួយ ។

**ប្រើតារាងវិវត្តន៍របស់កុមារសំរាប់កត់ត្រាការរីកចំរើនរបស់កុមារ**ជារៀងរាល់ខែ ឬពីរខែម្តង អ្នកអាចបន្ថែមរង្វង់ថ្មីទៅក្នុងតារាង ។ ចូរប្រើទឹកខ្មៅពិណខុសគ្នាជារៀងរាល់ពេល និងកត់ចំណាំកាលបរិច្ឆេទក្នុងពិណនិមួយៗ ។ បន្ទាប់មកបន្ថែមប្រអប់ ៤ ជ្រុង ដើម្បីកំណត់ជំហ៊ានវិវត្តបន្ទាប់ក្នុងជួរ ។

## តំរូវការសំរាប់ការជំរុញដំបូង

ឪពុកម្តាយ និងគ្រួសារជាគន្លឹះសំរាប់ការវិវត្តន៍ និងការសិក្សាដំបូងរបស់កុមារ ។ កុមារដែលយឺតក្នុងការវិវត្តន៍ត្រូវការការជំរុញដូចគ្នា( និយាយជាមួយគេ លេងល្បែង ការផ្សងព្រេង និងសេចក្តីស្រលាញ់ ) ដែលកុមារនីមួយៗត្រូវការ ។ ប៉ុន្តែពួកគេត្រូវការច្រើនជាងនេះ ។ ពួកគេត្រូវការជំនួយជាច្រើន និងសកម្មភាពដែលៗដើម្បីប្រើប្រាជ្ញា និងកាយរបស់ខ្លួន ។

**នៅពេលកុមារយឺតត្រូវការការជំរុញ និងសកម្មភាពផ្សេងៗ**
**ដើម្បីជួយអភិវឌ្ឍគ្រប់កន្លែងនៃរាងកាយ និងសតិរបស់គេ ។**

**កន្លែងវិវត្តរបស់កុមារដែលអាចត្រូវបានជួយតាមរយៈការជំរុញដំបូង និងការរៀនសកម្មភាព**



១. **ចលនា ការគ្រប់គ្រងសរីរាង្គកាយ កំលាំង និងលំនឹង**
សកម្មភាពនេះអាចជួយកុមារឱ្យធ្វើចលនាចុះឡើង ធ្វើអ្វីៗលេងនិងធ្វើការ ។



២. **ការប្រើដៃ :** បង្កើនការគ្រប់គ្រងដៃ និងការប្រើដៃឱ្យបានស្មើគ្នា ជាមួយវត្ថុអ្វីដែលកុមារឃើញ ដែលអនុញ្ញាតឱ្យ



៣. **វិញ្ញាណ** :ជាពិសេស ចក្ខុវិញ្ញាណ សោតវិញ្ញាណ និង វេទនារម្មណ៍ ។ ទាំងអស់នេះ នឹងជួយកុមារទទួលស្គាល់ និង ឆ្លើយតបនិងពិភពរបស់ខ្លួន ។



៤. **ការទំនាក់ទំនង :** ការស្តាប់ ការយល់អ្វីដែលគេនិយាយ និង រៀននិយាយ ឬទំនាក់ទំនងតាមមធ្យោបាយណាដែលអាច ធ្វើទៅបាន ។



៥. **ប្រតិកម្មជាមួយអ្នកដទៃ:** ញញឹម លេង ប្រព្រឹត្តត្រឹមត្រូវ និងរៀនចុះសម្រុងជាមួយអ្នកដទៃ



៦. **សកម្មភាពមូលដ្ឋានសំរាប់ការរស់នៅប្រចាំថ្ងៃ:** ការញុំា ការផឹក ការស្លៀកពាក់ និងការគ្រប់គ្រង ការបត់ជើងធំតូច (ជុះ និងនោម) ។ ជំនាញថែរក្សាខ្លួនឯងនេះជួយឱ្យកុមារ ឯករាជ្យបានច្រើន ។



៧. **ការសង្កេត ការគិត និងការធ្វើ:** រៀនពីវិធីធ្វើការសំរេចចិត្ត ដោយគិត និងដោយបញ្ញា

**ទិសដៅនៃកម្មវិធីការជំរុញដំបូង ដើម្បីជួយកុមារឱ្យអាចធ្វើបាន**
**គ្រប់គ្រាន់ចំពោះខ្លួនឯង រីករាយ និងមានចិត្តតាមដែលអាចធ្វើបាន ។**

## ជំហ៊ានក្នុងការរៀបចំកម្មវិធីសិក្សាពិសេស

**ទីមួយ:** សង្កេតកុមារយ៉ាងជិតដិត ដើម្បីវាយតំលៃអ្វីដែលកុមារអាចធ្វើបាន និងមិនអាចធ្វើទៅបាននៅក្នុងចំនុចវិវត្តន៍និមួយៗ ។

**ទីពីរ:** ចូរចំណាំពីវត្ថុអ្វីដែលកុមារទើបតែកំពុងចាប់ផ្តើមធ្វើ ឬកុមារនៅតែមានបញ្ហានៅឡើយ ។

**ទីបី:** សំរេចចិត្តពីជំនាញថ្មីអ្វីដើម្បីបង្រៀន ឬសកម្មភាពអ្វីដើម្បីលើកទឹកចិត្ត ដែលនឹងជួយកុមារកសាងជំនាញ ដែលគេមានស្រាប់ ។

**ទីបួន:** បែងចែកជំនាញថ្មីនិមួយៗ ជាជំហ៊ានតូចៗ : សកម្មភាពដែលកុមារអាចរៀននៅក្នុងរយ: ១ ឬ ២ ថ្ងៃបាន រួចទើបបន្តទៅជំហ៊ានបន្ទាប់ ។



***ប្រយ័ត្ន:*** មិនត្រូវរំពឹងខ្លាំងពេកនៅពេលភ្លាមទេ ។ ចូរប្រាកដនិយម ។ **ចូរផ្តើមពីអ្វីដែលកុមារអាចធ្វើបានល្អ** បន្ទាប់មកលើកទឹកចិត្តគេឱ្យធ្វើអ្វីច្រើនបន្តិចទៀត ដោយផ្តល់ជំនួយនៅពេលត្រឹមត្រូវ នោះអ្នកជួយ និងកុមារនឹងមានអារម្មណ៍ថាទទួលបានជោគជ័យ និងរីករាយ ។



## ការស្នើរសំរាប់រៀនពីសកម្មភាពកុមារឯទៀត (យឺត ឬមិនយឺត)

**ចូរអត់ធ្មត់ និងសង្កេត** កុមារមិនមែនរៀនរាល់ពេលឡើយ ជួនកាលពួកគេត្រូវការសំរាក ។ នៅពេលពួកគេត្រូវបានអោយសំរាក ពួកគេនឹងចាប់ផ្តើមលូតលាស់ជាថ្មី ។ ចូរសង្កេតកុមារឱ្យបានជិតដល់ ។ ចូរព្យាយាមយល់ពីវិធីដែលគេគិត អ្វីដែលគេ ស្គាល់ និងវិធីដែលគេប្រើជំនាញថ្មី ។ បន្ទាប់មកអ្នកនឹងរៀនពីវិធីជួយលំហាត់គេ និងកែលំអជំនាញទាំងនោះ ។ នៅពេលដែលនិយាយទៅកាន់គេ ចូរផ្តល់ពេលវេលាដល់គេ ដើម្បីឆ្លើយសំនួររបស់អ្នក ។ ចូរកែប្រែការនិយាយ ។ ចូរចាំថាលំហាត់ និងការធ្វើឡើងវិញច្រំដែលវាមានសារ:សំខាន់ណាស់ ។

**ចូរធ្វើតាមលំដាប់ និងមិនផ្លាស់ប្តូរ** ធ្វើផែនការសកម្មភាពពិសេស ដើម្បីឱ្យរីកចំរើនតាមធម្មជាតិ ពីជំនាញមួយទៅជំនាញមួយ ។ ចូរព្យាយាមលេងជាមួយកុមារនៅពេលដដែលៗជារៀងរាល់ថ្ងៃ និងដាក់តុក្កតា ឧបករណ៍ សំលៀកបំពាក់របស់កុមារ ។ល ។ នៅកន្លែងដដែល ។ ចូរប្រើតែរបៀបមួយនៃការបង្រៀន ការស្រលាញ់ និងការវិវត្តន៍ឥរិយាបថ ( ប្រសិនបើដំណើរការ) ។ ចូរធ្វើការឆ្លើយតបសកម្មភាព និងតំរូវការរបស់កុមារ ក្នុងវិធីដូចគ្នាក្នុងពេលនិមួយៗ ។ វិធីនេះនឹងជួយឱ្យកុមារយល់ និងមានអារម្មណ៍ជឿជាក់ និងសុវត្ថិភាព ។

**ចូរប្រើការផ្លាស់ប្តូរ** ព្រោះតែការធ្វើដដែលៗមានសារ:សំខាន់ ដូចនេះការផ្លាស់ប្តូរក៏មានសារ:សំខាន់ដែរ ។ ចូរធ្វើការផ្លាស់ប្តូរសកម្មភាពបន្តិចម្តងៗជារៀងរាល់ថ្ងៃ ធ្វើដូចនេះកុមារ និងអ្នកមិនទទួលការធុញទ្រាន់ ។ ធ្វើអ្វីៗក្នុងវិធីផ្សេងគ្នា និងនៅកន្លែងផ្សេងៗនៅក្នុងឬក្រៅផ្ទះ ។ ចូរនាំកុមារទៅផ្សារ ទីវាល និងស្ទឹងឬទន្លេ ។ ចូរផ្តល់កិច្ចការច្រើនឱ្យកុមារធ្វើ ។

**ចូរសម្តែងដោយមនោសញ្ចេតនា** ប្រើមុខ និងសំលេងដើម្បីបង្ហាញពីអារម្មណ៍ និងការគិតរបស់អ្នក ។ ចូរនិយាយឱ្យច្បាស់ និងសាមញ្ញ ( ប៉ុន្តែ ចូរកុំប្រើ " ការនិយាយបែបកូនក្មេង " ) ។ ចូរសសើរ និងលើកទឹកចិត្តកុមារឱ្យបានញឹកញាប់ ។

**ចូររីករាយ !** រកវិធីប្រែក្លាយរាល់សកម្មភាពទៅជាល្បែង ដែលធ្វើឱ្យកុមារ និងខ្លួនអ្នកគាប់ចិត្ត ។

**ចូរប្រតិបត្តិ** នៅពេលណាដែលអាចធ្វើទៅបាន ចូរជ្រើសរើសជំនាញ និងសកម្មភាពដែលនឹងជួយកុមារឱ្យចេះឯករាជ និងអាចធ្វើកិច្ចការបានច្រើនសំរាប់ខ្លួនគេ និងអ្នកដទៃ ។ ចូរជួយកុមារឱ្យចេះឯករាជ្យខ្លាំងឡើង ។ ចូរកុំការពារកុមារជ្រុលពេក ។

**ចូរជឿជាក់** កុមារទាំងអស់នឹងធ្វើការឆ្លើយតបតាមវិធីខ្លះ ដើម្បីរក្សា យកចិត្តទុកដាក់ និងស្រលាញ់ ។ ដោយមានជំនួយពីអ្នក កុមារដែលយឺតអាចក្លាយជាមានសមត្ថភាព និងឯករាជ្យច្រើនឡើងៗ ។

**កម្មវិធីសិក្សាពិសេសប្រសិនបើធ្វើផែនការបានល្អ និងធ្វើដោយប្រុង ប្រយ័ត្ន វាអាចជួយកុមារយឺតរីកលូតលាស់ច្រើនជាកុមារដែលគ្មានជំនួយ**

## គោលការណែនាំទូទៅសំរាប់ជួយក្នុងការវិវត្តន៍របស់កុមារ

វិធីដែលក្រុមគ្រួសារ និងអ្នកធ្វើការស្តារនីតិសម្បទារទំនាក់ទំនងជាមួយកុមារ នៅពេលដែលព្យាយាមបង្ហាត់ជំនាញថ្មីដល់កុមារ អាចធ្វើឱ្យខុសប្លែកគ្នាយ៉ាងខ្លាំងនៅក្នុងការវិវត្តន៍ទាំងមូល ។ វាអាចមានឥទ្ធិពលលឿន ឬល្អ នៅពេលកុមាររៀន ជំនាញថ្មី ។ សំខាន់ជាងនេះទៀត វាអាចមានឥទ្ធិពលលើការជឿជាក់ ឥរិយាបថ និងការប្រុងប្រៀបរៀនសូត្ររបស់កុមារ ។

មានវិធីសាស្ត្រធម្មតាមួយចំនួន ដែលអ្នកអាចប្រើសំរាប់ជួយកុមារ ឱ្យបានប្រសើរឡើងពី**ការស្វែងយល់អំពីសពាង្គកាយ របស់ខ្លួន រៀបចំឱ្យគេរៀនភាសា និងជួយឱ្យគេធ្វើទំនាក់ទំនងជាមួយមនុស្សផ្សេងតាមមធ្យោបាយរាក់ទាក់ និងសហការគ្នា ។**

គោលការណែនាំទាំងនេះ ប្រយោជន៍ជាពិសេសនៅពេលធ្វើការសិក្សាសកម្មភាពដំបូងជាមួយកុមារដែលយឺតក្នុងការវិវត្តន៍ :

១. **ចូរសសើរកុមារឱ្យបានច្រើន** សរសើរគេដោយក្តីស្រលាញ់ ឬផ្តល់ឱ្យគេនូវអំណោយបន្តិចបន្តួច នៅពេលដែល គេធ្វើអ្វីមួយបានល្អ ( ឬនៅពេលដែលគេធ្វើការខិតខំបានល្អ)



**ការពន្យល់**

សរសើរកិច្ចការដែលជ័យជំនះឱ្យបានច្រើន( និងចិត្តល្អច្រើនជាង) ការស្តីបន្ទោស ឬដាក់ទណ្ឌកម្មលើការបរាជ័យ ។ នៅពេលដែលកុមារព្យាយាមធ្វើអ្វីមួយ ហើយទទួលបរាជ័យ វាជាការប្រសើរជាងដែលធ្វើមិនដឹង ឬគ្រាន់តែនិយាយដូចនេះថា "អាក្រក់ណាស់ សំណាងល្អជាងនេះនៅពេលក្រោយ..." ។

***ប្រយ័ត្ន :*** **ជៀសវាងផ្តល់ស្ករ ឬអាហារជាអំណោយ ជាពិសេស ប្រសិនបើធាត់ ។**

២. **ចូរនិយាយឱ្យច្រើនជាមួយកុមារ** ការប្រើពាក្យច្បាស់ និងសាមញ្ញ និយាយអ្វីដែលអ្នកធ្វើជាមួយគេ ។



**ការពន្យល់**

កុមារស្តាប់ និងចាប់ផ្តើមរៀនភាសា មុនពេលដែលគេចាប់ផ្តើមនិយាយ ។ ទោះជាវាហាក់ដូចជាគេពុំយល់ ឬមិនអាចឆ្លើយ ក៏នៅតែព្យាយាមនិយាយទៅកាន់គេឱ្យបានច្រើន ។ ប្រសិនបើអ្នកគិតថាគេពុំឮ ចូរនិយាយជាមួយគេ ប៉ុន្តែប្រើ "សញ្ញាណភាសា" ផង ។ ចូរច្បាស់ថា គេមើលមកអ្នកនៅពេលអ្នកនិយាយ ។ ( មើលទំព័រ ១៣១ រហូតដល់ទំព័រ ១៣២)

៣. នៅពេលដែលអ្នកជួយកុមាររៀនជំនាញថ្មី **ចូរណែនាំចលនារបស់កុមារដោយដៃរបស់អ្នក** ឧទាហរណ៍ បង្រៀនកុមារអោយយកដៃដាក់មាត់ ( ឬញ៉ាំដោយខ្លួនឯង) អ្នកអាច :

ជួយគេដាក់ម្រាមដៃរបស់គេក្នុងអាហារដែលគេចូលចិត្ត | បន្ទាប់មកដាក់ដៃរបស់គេចូលទៅក្នុងមាត់ | បន្ទាប់ពីគេរៀនធ្វើដូចនេះរួច ចូរឱ្យគេធ្វើដោយខ្លួនឯង



**ការពន្យល់**

ជាធម្មតាវាដំណើរការបានប្រសើរ ដើម្បីណែនាំតិចៗដល់កុមារជាជាងប្រាប់គេពីវិធីធ្វើអ្វីមួយ ។ ប្រសិនបើគេព្យាយាមធ្វើអ្វីមួយ ប៉ុន្តែមានការលំបាក ដោយដឹកដៃរបស់គេដើម្បីឱ្យកុមារទទួលបានជ័យជំនះ នឹងធ្វើឱ្យគេអន្ទះសារៀនជំនាញថ្មីយ៉ាងខ្លាំង ប្រសិនបើអ្នកនិយាយថា "ទេចូរធ្វើវាយ៉ាងដូចនេះ!" ។

**៤. ចូរប្រើកញ្ចក់** ដើម្បីជួយកុមារឱ្យរៀនអំពីសរីរាង្គកាយរបស់ខ្លួន រៀនប្រើដៃរបស់ខ្លួន ។



**ការពន្យល់**

កញ្ចក់ជួយកុមារឱ្យមើលឃើញ និងសំគាល់សរីរាង្គកាយរបស់ខ្លួន ។ សារៈសំខាន់ពិសេស សំរាប់កុមារដែលមានការលំបាក ទាក់ទងនិងផ្នែកសរីរាង្គកាយផ្សេងៗរបស់ខ្លួន ឬឱ្យដឹងថាសរីរាង្គកាយនៅកន្លែងណាខ្លះ ។ (វិធីនេះអាចកើតឡើងនៅក្នុងទំរង់ខ្លះនៃការប្រាជ្ញាយឺត ជំងឺខូចខួរក្បាល ជំងឺរបួសសរសៃឆ្អឹងខ្នង និងជំងឺគមខ្នងពីកំណើត) ។

**៥. ចូរប្រើការត្រាប់តាម(ចំលងតាម)** បង្រៀនសកម្មភាព ឬជំនាញថ្មី ធ្វើអ្វីៗលើកដំបូង និងលើកទឹកចិត្តកុមារឱ្យចំលងតាមអ្នក ។ ចូរប្រែក្លាយវាឱ្យទៅជាល្បែង ។



**ការពន្យល់**

កុមារយឺតមួយចំនួន(ជាពិសេសកុមារទាំងឡាយណាដែលមានជំងឺយឺត=គ្រាសកន្លង) ចូលចិត្តចំលងតាម ឬធ្វើត្រាប់សកម្មភាពរបស់អ្នកដទៃ ។ នេះជាវិធីល្អសំរាប់បង្រៀនអ្វីៗជាច្រើនពីសកម្មភាពអាចមើលឃើញ រហូតដល់សំលេង និងពាក្យសម្តី ។

**៦. ចូរលើកទឹកចិត្តកុមារដើម្បីឱ្យឈោង ឬទៅរកអ្វីដែលគេចង់បាន**



នៅពេលដែលវាមានលក្ខណៈងាយស្រួលពេក ចូរដាក់ឧបសគ្គនៅតាមផ្លូវ ប៉ុន្តែកុំធ្វើឱ្យគេមានការលំបាកខ្លាំង ។

**ការពន្យល់**

ទោះជានៅក្នុងដំណាក់ដំបូងនៃការវិវត្តន៍ក៏ដោយ វាជាកំហុសមួយក្នុងការដាក់វត្ថុដែលកុមារចង់បាននៅក្នុងដៃរបស់គេជារឿយៗ ។ ជាជំនួស ចូរប្រើបំណងប្រាថ្នារបស់កុមារជាឱកាសមួយដើម្បីឱ្យគេប្រើការវិវត្តន៍ជំនាញកាយ និងជំនាញភាសាដើម្បីទទួលបាននូវអ្វីដែលគេចង់បានដូចជា ឈោង បង្វិល លើក វារ ឬអ្វីផ្សេងៗដែលគេកំពុងរៀនធ្វើ ។

**៧. ចូរធ្វើការសិក្សាដោយសប្បាយ** រកវិធីជានិច្ចកាល ប្រែក្លាយការសិក្សាសកម្មភាពឱ្យទៅជាល្បែង ។




**ការពន្យល់**

កុមាររៀនអស់ពីលទ្ធភាព និងសហការជាច្រើននៅពេលដែលពួកគេរីករាយ និងភ្ញាក់ផ្អើលពីអ្វីដែលពួកគេកំពុងតែធ្វើ ។ **ចូរបន្តធ្វើសកម្មភាព ដរាបណាវាជាការរីករាយសំរាប់កុមារ ។ នៅពេលដែលវាអស់ភាពរីករាយ ចូរបញ្ឈប់សកម្មភាពភ្លាម ឬធ្វើការផ្លាស់ប្តូរវាតាមវិធីខ្លះៗ ដោយបញ្ចូលការផ្សងព្រេង និងភាពភ្ញាក់ផ្អើលថ្មី ។**

៨. **ចូរឱ្យកុមារធ្វើឱ្យបានច្រើនតាមដែលគេអាចធ្វើទៅបានសំរាប់ខ្លួនរបស់គេ។ ជួយកុមារឱ្យបានច្រើនតាមអ្វីដែលគេត្រូវការ** ។ ឧទាហរណ៍ ប្រសិនបើកុមារមានបញ្ហាក្នុងការស្លៀកសំលៀងបំពាក់ ព្រោះតែការផ្លាស់ប្តូរ ចូរជួយគេដោយចំកោងស្មា និងខ្នងទៅមុខ ប៉ុន្តែអោយគេទាញពាក់សំលៀកបំពាក់ដោយខ្លួនឯងផ្ទាល់ ។




**ការពន្យល់**

នេះជា "ច្បាប់មាសនៃការស្តារនីតិសម្បទារ" ។ នៅពេលដែលកុមារមានបញ្ហាក្នុងការធ្វើអ្វីមួយ ឬហាក់ដូចជាយឺត ឬឆ្គាំងឆ្គង ឪពុកម្តាយតែងតែចង់ "ជួយ" ធ្វើកិច្ចការនោះជំនួសកុមារ ។ ប៉ុន្តែចំពោះការវិវត្តន៍របស់កុមារវានឹងជួយគេច្រើននៅពេលដែលអនុញ្ញាតឱ្យគេធ្វើដោយខ្លួនឯង ដូចជាការផ្តល់ការលើកទឹកចិត្ត ប៉ុន្តែជួយត្រឹមតែវិធីដែលធ្វើឱ្យកុមារធ្វើឱ្យបានច្រើនសំរាប់ខ្លួនឯង ។

៩. **កុមារតែងតែធ្វើអស់ពីសមត្ថភាព នៅពេលដែលគ្មានវត្តមានរបស់គ្រូ**




**ការពន្យល់**

កុមារតែងតែព្យាយាមបំផុត នៅពេលដែលពួកគេចង់ធ្វើអ្វីច្រើន និងគ្មានអ្នកនៅទីនោះដើម្បីជួយគេ។ ការបង្រៀនមានសារៈសំខាន់ចាំបាច់ ប៉ុន្តែការផ្តល់ឱកាសឱ្យគេស្វែងរកក៏មានសារៈសំខាន់ដែរ ធ្វើការសាកល្បងព្រំដែនរបស់ខ្លួន និងធ្វើអ្វីៗដោយខ្លួនឯងផ្ទាល់ ។

១០. **ចូរឱ្យបងស្រី ឬបងប្រុសចង្អុលបង្ហាញពីឧបករណ៍ថ្មី**




**ការពន្យល់**

កុមារខ្លះអាចបដិសេធមិនព្យាយាម ឬខ្លាចមិនលេងរបស់ថ្មីជំនួយថ្មី ឬកន្លែងអង្គុយពិសេស ។ ប្រសិនបើកុមារផ្សេងទៀតសាកល្បងមុន រួចបង្ហាញគេ ដូចនេះគេនឹងព្យាយាមដែរ ។

*ចូរចងចាំ* **: ការបង្រៀនល្អ** *នឹង* **ធ្វើអោយមានភាពផ្សេងគ្នា។ អ្នកបង្រៀនលេង និងសំដែងការស្រលាញ់** ***ល្អយ៉ាងណា*** **គឺសំខាន់ជាងពេលវេលា** ***ជាច្រើន*** **ដែលអ្នកចំណាយចំពោះវា។**



កុមារដែលយឺតខាងប្រាជ្ញា រៀនពីផ្នែកផ្សេងៗនៃមុខ ដោយដាក់ក្រដាសកាត់តុងដែលត្រូវបានកាត់ជាផ្នែកនៅលើមុខក្រដាស ។ ( សាមាដហាន ទីក្រុងដេលី ប្រទេសឥណ្ឌា)



តុក្កតាអាយ៉ង ត្រូវបានប្រើដើម្បីបង្រៀនកុមារដែលយឺតខាងប្រាជ្ញានៅឯសាមាដហាន ( ប្រទេសឥណ្ឌា) ។ អាយ៉ងនិមួយៗស្លៀកសំលៀកបំពាក់ដែលមានពណ៌មួយ និងមានឈ្មោះរបស់ពណ៌នោះ ។ កុមាររៀនពីឈ្មោះអាយ៉ង និងរៀនពីឈ្មោះពណ៌ផងដែរ ។